# ជំពូកថ្មីមួយ

ដោយ ជេន ម៉ាកប្រាយដ៍
ផ្អែកទៅលើដំណើររឿងពិត

« *ពរជ័យជាច្រើនទាំងនេះបានធ្វើឲ្យខ្ញុំទទួលអារម្មណ៍មានអំណរគុណជាខ្លាំងដើម្បីក្លាយជាខ្លួនខ្ញុំ* » ( Children's Songbook *ទំព័រ ១១* ) ។



សារ៉ាបានបើកប្រអប់មួយពេលម្ដាយនាងបានដើរចូលមកក្នុងបន្ទប់ ។

នាងបានសួរម៉ាក់នាងថា « តើយើងអាចលាបជញ្ជាំងផ្ទះពណ៌លឿងបានទេ ? »

ពួកគេទើបតែប្ដូរមករស់នៅផ្ទះមួយផ្សេងទៀត ។ សារ៉ាអាចជ្រើសរើសភួយមានញាត់សំឡី និងវាំងននសម្រាប់បន្ទប់ថ្មីរបស់នាង !

ម្ដាយពោលថា « ម៉ាក់គិតថាអាចលាបបាន។ ពណ៌លឿងគឺជាពណ៌រីករាយ » ។

សារ៉ាបានដាក់សៀវភៅមួយចំនួននៅលើធ្នើរក្បែរគ្រែគេងរបស់នាង ។ ម៉ាក់នាងពុំមានអារម្មណ៍ *រីករាយ* ជានិច្ចទេមួយរយៈពេលក្រោយនេះ ចាប់តាំងពីប៉ារបស់នាងបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍មក ។ សារ៉ាបានដាក់រូបថតប៉ារបស់នាងដែលនាងចូលចិត្តដោយប្រុងប្រយ័ត្ននៅជាប់នឹងសៀវភៅនោះ ជាកន្លែងដែលនាងអាចឃើញរូបថតនោះរៀងរាល់ព្រឹកពេលនាងភ្ញាក់ពីគេង ។

នាងបានឮសំឡេងយំខ្សឹកខ្សួល ហើយបានឃើញទឹកភ្នែកនៅក្នុងភ្នែករបស់ម៉ាក់នាង ។

សារ៉ាបាននិយាយទាំងឱបចង្កេះម្ដាយនាងយ៉ាងណែនថា « កូនស្រឡាញ់ម៉ាក់ » ។

« ម៉ាក់ស្រឡាញ់កូនខ្លាំងណាស់ » ។

នៅថ្ងៃសៅរ៍ពីមុនចាប់ផ្ដើមចូលរៀន ម៉ាក់សារ៉ា និងសារ៉ាបានស្លៀកពាក់ខោអាវចាស់ៗ រំកិលគ្រឿងសង្ហារិមទៅកណ្ដាលបន្ទប់របស់សារ៉ា ហើយទាញរទ្បូលាបថ្នាំជញ្ជាំងនៅក្នុងថាសលាបថ្នាំពណ៌លឿងដោយប្រុងប្រយ័ត្ន ។ មួយសន្ទុះក្រោយមកជញ្ជាំងបានលាបពណ៌លឿងរួច—ហើយមុខ និងខោអាវពួកគេក៏មានប្រឡាក់ថ្នាំផងដែរ !

រចនារូបភាពដោយ អេនឌី អ៊ីលីយ៉ត

ម៉ាក់នាងបាននិយាយទាំងសើចថា « មើលទៅកូន ដូចជាត្រូវពន្លឺព្រះអាទិត្យខ្ទាតប្រឡាក់អញ្ចឹង » ។

សារ៉ាបានសើចកក្អឹក ។ « ហើយមើលទៅម៉ាក់ដូចជាមានចេកមួយដែលខ្ទាតនៅជាប់ម៉ាក់អញ្ចឹង ! »

ពួកគេនៅតែសើច ពេលពួកគេសម្អាតខ្លួន ។ ប៉ុន្តែស្នាមញញឹមរបស់សារ៉ាបានរសាយបាត់ ពេលនាងបានគិតអំពីការទៅថ្នាក់អង្គការបឋមសិក្សានៅថ្ងៃស្អែក និងទៅរៀននៅថ្ងៃបន្ទាប់នោះ ។



នាងបានប្រាប់ម៉ាក់នាងពេលពួកគេលាងជក់លាបថ្នាំនៅកន្លែងលាងដៃ « កូនបារម្ភអំពីព្រះវិហារ និងសាលាថ្មីរបស់កូន ។ « កូនមិនស្គាល់គ្រូបង្រៀន ឬកុមារ ឬនរណាម្នាក់ទេ » ។

ម៉ាក់បានបិទទឹក ហើយទាញសារ៉ាឱប ។

« កូននឹងមានមិត្ត ។ កូនមានសន្ដានចិត្តល្អ នោះមនុស្សដទៃនឹងរាប់អានកូនហើយ ។ ចូរធ្វើខ្លួនជាក្មេងល្អបំផុត ហើយកូននឹងមានមិត្ត » ។

សារ៉ាមានអារម្មណ៍ល្អជាងមុន ប៉ុន្តែនាងនៅតែភ័យខ្លាច ។

នាងនិយាយថា « ខ្ញុំចង់ឲ្យប៉ានៅទីនេះ ដើម្បីផ្ដល់ការប្រសិទ្ធពរមួយដល់ខ្ញុំ ។ ដូចគាត់ធ្លាប់ធ្វើជានិច្ច ពីមុនខ្ញុំត្រឡប់ចូលរៀនវិញ » ។

ម៉ាក់បាននៅស្ងៀមមួយសន្ទុះ ។ គាត់បាននិយាយថា « ចុះលោកពូយ៉ាត់នោះ ? ម៉ាក់ប្រាកដចិត្តថា គាត់រីករាយនឹងផ្ដល់ការប្រសិទ្ធពរមួយដល់កូន » ។

សារ៉ាបានងក់ក្បាល ។ ប្រហែលជាការប្រសិទ្ធពរមួយអាចជួយបាន ។

នៅយប់នោះ ពូរបស់សារ៉ាបានដាក់ដៃគាត់លើក្បាលរបស់នាង ហើយផ្ដល់ការប្រសិទ្ធពរមួយឲ្យនាង ។

គាត់បាននិយាយថា « ពូសូមប្រសិទ្ធពរក្មួយឲ្យដឹងថា ព្រះអង្គសង្គ្រោះព្រះតម្រិះពីក្មួយ ពេលក្មួយចាប់ផ្ដើមជំពូកថ្មីនៅក្នុងជីវិតនេះ ។ ទ្រង់មិនចោលក្មួយឲ្យនៅកំព្រាទេ » ។

សារ៉ាបានផ្ដោតចិត្តទុកដាក់លើពាក្យ *ជំពូកថ្មី* ។ នាងចូលចិត្តអាន ហើយមានចិត្តរំភើបជានិច្ច ដើម្បីចាប់ផ្ដើមអានជំពូកថ្មីមួយក្នុងសៀវភៅ ។

នៅថ្ងៃបន្ទាប់សារ៉ា និងម៉ាក់បានទៅព្រះវិហារ ។ បន្ទាប់ពីការប្រជុំសាក្រាម៉ង់រួច ម្ដាយបានជួយសារ៉ាស្វែងរកបន្ទប់ថ្នាក់អង្គការបឋមសិក្សា ។ ក្មេងស្រីម្នាក់នៅក្នុងថ្នាក់បានញញឹមដាក់នាង ហើយបាននិយាយថាសួស្ដី ។

ក្មេងស្រីនោះនិយាយ ដោយគោះដៃលើកៅអីទទេនៅជាប់នឹងនាងថា « អ្នកអាចអង្គុយទីនេះបានប្រសិនបើអ្នកចង់ » ។

សារ៉ាបានពោលថា « អរគុណ ។ ខ្ញុំឈ្មោះសារ៉ា ។ ខ្ញុំជាអ្នកចំណូលថ្មីនៅទីនេះ » ។

« ខ្ញុំឈ្មោះមេឡូឌី ។ ខ្ញុំក៏ជាអ្នកចំណូលថ្មីដែរ ! នេះគឺជាសប្ដាហ៍ទីពីររបស់ខ្ញុំ » ។

មិនយូរប៉ុន្មានក្រោយមក មេឡូឌី និងសារ៉ាបាននិយាយជាមួយកុមារដទៃទៀតនៅថ្នាក់អង្គការបឋមសិក្សា ។ គ្រូបង្រៀនរបស់ពួកគេរីករាយរាក់ទាក់ណាស់ ។

« ខ្ញុំសង្ឃឹមថា សាលារៀនក៏មានសភាពល្អបែបនេះដែរ ! សារ៉ាបានគិតពេលនាងបានចូលគេងនៅយប់នោះ ។

នៅថ្ងៃបន្ទាប់ សារ៉ាបានជិះឡានក្រុងទៅសាលារៀនថ្មីរបស់នាង ។ នាងមានចិត្តរំភើបដើម្បីឃើញកុមារមួយចំនួនមកពីថ្នាក់បឋមសិក្សា រៀននៅថ្នាក់ទីបីជាមួយនាងដែរ ។

សារ៉ាបានអធិស្ឋានដោយស្ងាត់ៗ ពេលនាងញ៉ាំអាហារថ្ងៃត្រង់ជាមួយមិត្តថ្មីរបស់នាងថា « ឱព្រះវរបិតាសួគ៌អើយ សូមអរព្រះគុណទ្រង់ ។ នេះប្រហែលជាជំពូកល្អមួយនៃជីវិត បន្ទាប់ពីអ្វីៗទាំងអស់ » ។ ●

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា.* ។